**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :..........០៩២/១៦.........ក.ប/ស.ជ.ព

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣០ ទិវាពលកម្មអន្តរជាតិ
# ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦

យោងអនុក្រឹត្យលេខ១៣៧អនក្រ/បក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥ ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០១៦ និងប្រកាសលេខ៤១៦កប/ប្រក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ ស្តីពីការឈប់បុណ្យដែលមានប្រាក់ឈ្នួលសម្រាប់ឆ្នាំ២០១៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសូមជូនដំណឹងដល់គ្រប់មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត សមាគមនិយោជក និងនិយោជក សហភាពសហព័ន្ធសហជីព និងសហព័ន្ធសហជីព ព្រមទាំងកម្មករនិយោជិតនៃសហគ្រាស គ្រឹះស្ថានទាំងអស់ ដូចខាងក្រោម៖

១-គ្រប់មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត ទាំងអស់ ត្រូវណែនាំឱ្យមានការរៀបចំ ប្រារព្ធពិធីខួបអនុស្សាវរីយ៍លើកទី១៣០ ទិវាពលកម្មអន្តរជាតិ ១ ឧសភា ក្រោមប្រធានបទ "**លើកកម្ពស់សេរីភាពអង្គការវិជ្ជាជីវៈ និងស្ថិរភាពផលិតកម្ម ដើម្បីបង្កើនផលិតភាព និងការងារ**" ឱ្យមានភាពអធិកអធមស័ក្តិសមជាបុណ្យការងាររបស់ពលករកម្ពុជា និងជាថ្ងៃឈប់សម្រាករបស់មន្ត្រីរាជការ និងកម្មករនិយោជិតទាំងអស់។ ក្នុងន័យនេះ ត្រូវចាត់តាំងឱ្យមានការចងបដាពាក្យស្លោកនៅតាមដងផ្លូវសំខាន់ៗ មន្ទីរនានា និងសហគ្រាស គ្រឹះស្ថានរាជធានី ខេត្តរបស់ខ្លួន។

គ្រប់មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត និងសហព័ន្ធសហជីព គប្បីចាត់តាំងពិធីជួបជុំសំណេះសំណាលអបអរសាទរទិវាពលកម្មអន្តរជាតិ ១ ឧសភា នៅតាមសហគ្រាស គ្រឹះស្ថាន ទីស្នាក់ការសហព័ន្ធសហជីព ដើម្បីផ្សព្វផ្សាយសារលិខិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សារាចរណែនាំរបស់រាជរដ្ឋាភិបាល និងសេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងប្រារព្ធពិធីកម្សាន្តសប្បាយរីករាយតាមរូបភាព និងលទ្ធភាពជាក់ស្តែង។

ទន្ទឹមនឹងនេះ អស់លោក-លោកស្រី ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងការការពារថែរក្សាសន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ដើម្បីបង្កលក្ខណៈងាយស្រួលដល់កម្មវិធីសប្បាយរីករាយរបស់កម្មករនិយោជិតតាមសហគ្រាស គ្រឹះស្ថាន ដែលបោះទីតាំងក្នុងមូលដ្ឋាន។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

Scanned by CamScanner

២-គ្រប់ក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន ត្រូវចាត់ចែងឱ្យមានការឈប់សម្រាកនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦។ ក្នុងករណីចាំបាច់បំផុតដែលសហគ្រាស គ្រឹះស្ថាន មិនអាចបញ្ឈប់សកម្មភាពរបស់ខ្លួនបាន ក្នុងឱកាសថ្ងៃឈប់បុណ្យនេះបានទេ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវសម្របសម្រួលជាមួយកម្មករ និយោជិតឱ្យមានការស្ម័គ្រចិត្ត។ កម្មករនិយោជិតដែលធ្វើការថ្ងៃឈប់បុណ្យនេះ មានសិទ្ធិទទួលនូវការឈប់សម្រាកសងនៅថ្ងៃណាមួយក្នុងសប្តាហ៍ ឬទទួលប្រាក់បំណាច់ដែលមានចំនួនស្មើនឹងប្រាក់ឈ្នួលថ្ងៃធ្វើការធម្មតា។

៣-សហភាពសហព័ន្ធសហជីព សហព័ន្ធសហជីព និងសហជីព តាមសហគ្រាស គ្រឹះស្ថានត្រូវសម្របសម្រួល និងសហការជាមួយនិយោជក ដើម្បីចាត់តាំងការជួបជុំសំណេះសំណាលតាមសហគ្រាស គ្រឹះស្ថានទទួលអំណរទិវាពលកម្មអន្តរជាតិ ១ ឧសភា ឬចាត់តាំងពិធីកំសាន្តសប្បាយរីករាយតាមរូបភាពផ្សេងៗ និងតាមលទ្ធភាពរៀងៗខ្លួន ដើម្បីបង្កបរិយាកាសសាមគ្គីភាព និងភាពសុខដុមរមនា នៅតាមសហគ្រាស គ្រឹះស្ថាន។

៤-សហភាពសហព័ន្ធសហជីព សហព័ន្ធសហជីព និងសហជីព តាមសហគ្រាស គ្រឹះស្ថាន ពុំគប្បីយកឱកាសទិវាពលកម្មអន្តរជាតិ ១ ឧសភា ដែលជាថ្ងៃបុណ្យការងារ និងជាថ្ងៃឈប់សម្រាកការងាររបស់កម្មករនិយោជិត ដើម្បីបង្កនូវបាតុភាពទាំងឡាយណាដែលនាំឱ្យមានអំពើហិង្សា ឬរំខានដល់គោលបំណងខាងលើឡើយ។

៥-រៀបចំមិទ្ទីញ និងវេទិកាការងារនៅតាមគ្រប់រាជធានី ខេត្ត ដើម្បីពិភាក្សាស្វែងរកដំណោះស្រាយលើបញ្ហា ឬសំណូមពរ ជាអាទិភាពរបស់បងប្អូនកម្មករនិយោជិត និងនិយោជក។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីសង្ឃឹមយ៉ាងមុតមាំថា មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត សមាគមនិយោជក និងនិយោជក ព្រមទាំងសហភាពសហព័ន្ធសហជីព សហព័ន្ធសហជីព និងកម្មករនិយោជិតនៃសហគ្រាស គ្រឹះស្ថានទាំងអស់ នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០១៦

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**ចម្លងជូន៖**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការ
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត
-គ្រប់សមាគមនិយោជក
-គ្រប់សហព័ន្ធសហជីព
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-ឯកសារ-កាលប្បវត្តិ



Scanned by CamScanner